ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៦៦/១៤ - កាល់លីស្តូ អ៊ីភើរីល (ខេមបូឌា)

កាលបរិច្ឆេទនៃសេចក្តីបង្គាប់៖ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៤

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ុង សុទ្ធី**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **វ៉ែន ពៅ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន កាល់លីស្តូ អ៊ីភើរីល (ខេមបូឌា)**

អាសយដ្ឋាន ៖ ផ្លូវទំនប់កប់ស្រូវ ភូមិស្រែរាជ្ជៈ សង្កាត់សំរោងក្រោម ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៦៨ ៩៥៥ ៥៨៧ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

- លោក លី គីមអាន តំណាងរោងចក្រ

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ - **សហព័ន្ធសហជីពស្មារតីកម្មករខ្មែរ**

អាសយដ្ឋាន ៖ ភូមិជង្រុក សង្កាត់ត្រពាំងក្រសាំង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៩ ៧៨៤ ៦៧៧ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

- លោក មុំ សុភ័ស្ត មន្ត្រីសម្របសម្រួលសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនបញ្ឈប់ប្រធានផ្នែករដ្ឋបាលឈ្មោះ នៅ ប៊ុនឃាង ហៅ ហុង ចេញពីការងារ ព្រោះគាត់បានប្រើពាក្យសំដីមិនសមរម្យមកលើកម្មករ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនពុំមានគោលការណ៍បញ្ឈប់លោក នៅ ប៊ុនឃាង ពីការងារនោះទេ ព្រោះគាត់ពុំមានកំហុសដូចការចោទប្រកាន់ឡើយ។

២- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១៥ ដុល្លារ ក្នុងមួយខែ និងកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់នេះជាសមាមាត្រ ពេលដែលកម្មករនិយោជិតសុំច្បាប់ឈប់សំរាក មានធុរៈផ្សេងៗ ដែលមានការអនុញ្ញាតពីក្រុមហ៊ុន។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននៅតែរក្សាជំហរដដែល គឺផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ដល់កម្មករនិយោជិតចំនួន ១០ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគី និយោជកបញ្ជាក់ថា បើកម្មករឈប់ក្នុងរយៈពេល ១៥ ថ្ងៃដំបូងមានច្បាប់ ចាប់ពីមួយថ្ងៃដល់មួយថ្ងៃកន្លះ ក្រុមហ៊ុននឹងកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ជាសមាមាត្រ។ ប៉ុន្តែ បើកម្មករឈប់មានច្បាប់លើសពីមួយថ្ងៃកន្លះទៅ ក្រុមហ៊ុននឹងកាត់ប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ០៥ ដុល្លារ។

៣- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅចំនួន ១០ ដុល្លារ ក្នុងមួយខែ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននៅតែរក្សាជំហរដដែល គឺផ្តល់សោហ៊ុយធ្វើដំណើរ និងស្នាក់នៅដល់កម្មករនិយោជិតចំនួន ០៧ ដុល្លារ ក្នុងមួយខែ។

៤- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់អាហារថ្ងៃត្រង់ចំនួន ៤០០០ រៀល ក្នុងមួយថ្ងៃ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុននៅតែរក្សាជំហរដដែល គឺផ្តល់ប្រាក់ជួសអាហារថ្ងៃត្រង់ចំនួន ១០០០ រៀល សម្រាប់កម្មករម្នាក់ក្នុងមួយថ្ងៃ។

៥- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនចេញប៊ុងបើកប្រាក់ឈ្នួលឱ្យបានមុនថ្ងៃបើកប្រាក់ឈ្នួលចំនួន ០២ ថ្ងៃ។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនអាចកំណត់ពេលច្បាស់លាស់ក្នុងការចេញប៊ុង បើកប្រាក់ឈ្នួលឱ្យកម្មករនិយោជិតបានទេ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ(ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៩៥ កប/ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ (អាណត្តិទី១១)។

THE ARBITRATION COUNCIL

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូក ទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ៣២៨ កប/អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ត្រូវបានបញ្ជូន មកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤។

**សវនាការ និង សង្ខេបនីតិវិធី**

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ នាយកដ្ឋានវិវាទការងារ បានទទួលបណ្តឹងតាមទូរស័ព្ទពីថ្នាក់ដឹកនាំ សហជីពស្មារតីកម្មករខ្មែរ ស្តីពីកម្មករនិយោជិតធ្វើកូដកម្មទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារមួយចំនួនឱ្យ បានល្អប្រសើរ។ បន្ទាប់ពីបានទទួលបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយ វិវាទការងារនេះដល់ទីតាំងរោងចក្រ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤ ដដែល ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ០៩ ចំណុចលើការទាមទារចំនួន ១៤ ចំណុច។ ចំណុចមិនសះជាទាំង ០៥ ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុម ប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន កាល់លីស្តូ អីភេរីល (ខេមបូឌា) លេខ ៣២៨ កប/អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤។

ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលព័ត៌មានថា កូដកម្មនៅតែបន្ត បន្ទាប់ពីសំណុំរឿងត្រូវបានបញ្ជូនមក ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានទទួលលិខិតមួយច្បាប់របស់ក្រុមហ៊ុន កាលីស្តូ អីភេរីល (ខេមបូឌា) ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីសំណើសុំឱ្យប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចេញលិខិតបញ្ជាផ្អាក ធ្វើកូដកម្មជាបន្ទាន់ ដែលការធ្វើកូដកម្មរបស់កម្មករនិយោជិត បានចាប់ផ្តើមពីថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៤ មក។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញ សេចក្តីបញ្ជា លេខ ០១៤/១៤ កបអ. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ ឱ្យកូដករផ្អាកជាបន្ទាន់នូវការធ្វើកូដកម្មនៅក្រុមហ៊ុន កាល់លីស្តូ អីភេរីល (ខេមបូឌា) រហូតដល់នីតិវិធីនៃអាជ្ញា កណ្តាល ត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៤ តទៅ តាមវេនរបស់ខ្លួន។ យ៉ាងណាមិញ ក្រោយការចេញសេចក្តីបញ្ជានេះ កូដករនៅតែបន្តធ្វើ កូដកម្មដដែល ដោយកូដករមិនបានគោរពតាមសេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ។

យោងតាមកំណត់ហេតុស្តីពី ការទទួលព័ត៌មាន របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមរយៈទូរស័ព្ទ ពីលោក លី គឹមអាន ជាអ្នកតំណាងឱ្យក្រុមហ៊ុន កាល់លីស្តូ អីភេរីល (ខេមបូឌា) នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ វេលាម៉ោង ១៤៖៤០ នាទីរសៀល ថា កម្មករនិយោជិតមិនបានចូលធ្វើការវិញតាមបញ្ជារបស់ក្រុមអាជ្ញាកណ្តាលនោះទេ ដោយ កម្មករនិយោជិតចំនួនប្រមាណជា ៤០ ទៅ ៥០ នាក់ នៅតែបន្តធ្វើកូដកម្មនៅខាងក្រៅរោងចក្រដដែល។ តាមរយៈ កំណត់ហេតុស្តីពី ការទទួលព័ត៌មាន ពីកម្មករនិយោជិត ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ ដដែល លេខាធិការដ្ឋានក្រុម ប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានតាមរយៈទូរស័ព្ទ ពីលោក មុំ សុភ័ស្ត នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ វេលា ម៉ោង ១៤៖៤៥ នាទីរសៀល ថា កម្មករនិយោជិតភាគច្រើននៅតែបន្តការធ្វើកូដកម្មនៅខាងក្រៅរោងចក្រដដែល។



THE ARBITRATION COUNCIL

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេចដូចខាងក្រោម៖

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- ពាក្យសុំឱ្យចេញលិខិតបញ្ជារបស់ក្រុមហ៊ុន កាល់លីស្គូ អ៊ីភេរីល (ខេមបូឌា) ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤ គោរពជូន ប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំឱ្យប្រធានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចេញលិខិតបញ្ជាផ្អាកធ្វើកូដកម្មជាបន្ទាន់។

២- ដីកាសម្រេចរក្សាការពារលេខ ០៦ "ណ" ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ ស្តីពីប្តឹងសុំឱ្យតុលាការចេញដីកាសម្រេចរក្សាការពារ។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន កាល់លីស្គូ អ៊ីភេរីល (ខេមបូឌា) លេខ ៣២៨ កប/អក/វក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៤។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន កាល់លីស្គូ អ៊ីភេរីល (ខេមបូឌា) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៤។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតលេខ ៣០៦ កប/អក/វក/លកអ. របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ជម្រាបមក លោកប្រធានសហព័ន្ធសហជីពស្មារតីកម្មករខ្មែរ ស្តីពីការជ្រើសរើសក្រុមអាជ្ញាកណ្តាល។

២- កំណត់ហេតុ ស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាល ពីបញ្ជីឈ្មោះអាជ្ញាកណ្តាលស្នើដោយសហជីពកម្មករនិយោជិត ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤។

៣- សេចក្តីបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០១៤/១៤ កបអ. ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤។

៤- កំណត់ហេតុទទួលព័ត៌មានពីភាគីនិយោជក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤។

៥- កំណត់ហេតុទទួលព័ត៌មានពីភាគីកម្មករនិយោជិត ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤។

**អង្គហេតុ**

មិនមានការរកឃើញអង្គហេតុ ទាក់ទងទៅនឹងចំណុចបញ្ហាវិវាទនៅក្នុងរបាយការណ៍មិនសះជា ដែលនាយកដ្ឋានវិវាទការងារបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ ដោយសារក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបានដំណើរការសវនាការ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាលដែរ ឬទេ?

ប្រការ ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចែងថា៖ “*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ (ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម* ”។

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើរការអាជ្ញាកណ្តាល។

នៅក្នុងសេចក្តីបង្គាប់មុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយមាត្រានេះថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាភាគីកម្មករនិយោជិត កំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ *៥៩/០៦-សាង វ៉ូ, លេខ ៣៥/០៨-ចុង យ៉ូវ, លេខ ១៣៧/០៩, ១៣៨/០៩-ញ៉ូ ភាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ១១៥/១៣-ពូ យៀន, និងលេខ ០១៩/១៤-ដុងឌូ ថេកស្តាយ (ខេមបូឌា))*។

ឧទាហរណ៍ នៅក្នុងសំណុំរឿងលេខ ០៤/០៤-អិម អេស អាយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីជូនដំណឹងមួយ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៤ ដែលកថាខ័ណ្ឌទី៤ នៃសេចក្តីជូនដំណឹងនេះ កំណត់ថា ៖

“*ដោយពិនិត្យឃើញថា ភាគីនៃវិវាទការងារនេះមិនមានសិទ្ធិធ្វើកូដកម្ម ក្នុងកំឡុងពេលនៃដំណើរការរបស់អាជ្ញាកណ្តាល ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចធ្វើការដោះស្រាយ ឬក៏ចេញសេចក្តីបង្គាប់លើវិវាទការងាររួមនេះបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលឡើយ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលអាចដោះស្រាយវិវាទការងាររួមនេះម្តងទៀតបាន នៅពេលណាដែលសហជីពកម្មករនិយោជិតទាំងអស់ឈប់ធ្វើកូដកម្ម* ”។

ដូចគ្នាដែរ នៅក្នុងសំណុំរឿងលេខ ១៨/០៤-សណ្ឋាគារ (កាំបូឌីយ៉ាណា, រ៉ាហ្វែល ឡឺរ៉ូយ៉ាល់, រ៉ាហ្វល ប្រែគ្គឌិ អង្គរ, សាន់វេ, អ៊ិនធើខនធីណេនថល និងសូហ្វីតែល អង្គរ) ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទីពីរ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៤ ដែលចំណុចទី៩ និងទី១១ នៃសេចក្តីបញ្ជានេះ ចែងដូចខាងក្រោម ៖

“*ចំណុចទី៩- ចាប់ពីថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៤ តទៅ កម្មករនិយោជិតទាំងអស់ត្រូវបញ្ឈប់កូដកម្ម បាតុកម្ម ឬការរំខានណាមួយ នៅក្នុងបរិវេណសណ្ឋាគារនានា ដែលជាភាគីនៃវិវាទនេះ* ”។

“*ចំណុចទី ១១-ក្រុមប្រឹក្សាអាជ្ញាកណ្តាលរក្សាសិទ្ធិក្នុងការបញ្ចប់ដំណើរការអាជ្ញាកណ្តាល ករណីដែលភាគីណាមួយបំពានប្រការណាមួយនៃសេចក្តីបញ្ជានេះ* ”។

នៅក្នុងសំណុំរឿងលេខ ៧៧/០៥-ប្រ៊្វង់កូ ទីតធីង ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាទី២ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៥ ហើយបានចែងនៅក្នុងចំណុចទី៤ ថា នៅក្នុងករណីដែលភាគីកម្មករនិយោជិតបន្តធ្វើ

THE ARBITRATION COUNCIL

កូដកម្ម ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងមិនដំណើរការដោះស្រាយវិវាទការងាររួមនេះទេ។

នៅក្នុងសំណុំរឿងលេខ ១១០/១១-ស៊ីម៉ាណូ និងសំណុំរឿងលេខ ១៧/១៣-អ៊ិនធើណាស្យូណាល់ ហ្វេសិន រ៉ូយ៉ាល់ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏បានចេញសេចក្តីបង្គាប់មិនបន្តដំណើរការអាជ្ញាកណ្តាល ដោយមូលហេតុ កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ក្នុងអំឡុងពេលដំណើរការនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលដែរ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របតាមការសម្រេច របស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលក្នុងសំណុំរឿងខាងលើដែរ។

យោងតាមកំណត់ហេតុស្តីពី ការទទួលព័ត៌មាន របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៤ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលព័ត៌មានដូចគ្នាពីភាគីទាំងពីរថា កម្មករនិយោជិតនៅតែបន្តធ្វើកូដកម្ម ដោយមិនគោរពតាមសេចក្តីបញ្ជា របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៤ ឡើយ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបញ្ចប់ដំណើរការអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ៖

## សម្រេច និង បង្គាប់

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ ៦៦/១៤-កាល់លីស្តូ អីភេរីល (ខេមបូឌា)។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក**

ឈ្មោះ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត**

ឈ្មោះ៖ **ម៉ែន ពៅ**

ហត្ថលេខា៖ ------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល**

ឈ្មោះ៖ **ម៉ែន ប៊ុនឈា**

ហត្ថលេខា៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល THE ARBITRATION COUNCIL